ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# ប្រទេសជប៉ុនផ្តល់ជំនួយថវិកាចំនួន ១.៣៩ លានដុល្លារសហរដ្ឋអាមេរិកដល់ អ.វ.ត.ក

រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់ជំនួយថវិកាថ្មីមួយទៀត ចំនួន ១ ៣៨៥ ៥៦៧ ដុល្លារសហរដ្ឋអាមេរិក ដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ ជប៉ុន គឺជាប្រទេសផ្តល់ជំនួយធំបំផុតរបស់ អ.វ.ត.ក ហើយជាមួយការផ្តល់វិភាគទានថ្មីបន្ថែមនេះ ប្រទេសជប៉ុនបានផ្តល់ជំនួយហិរញ្ញវត្ថុដល់សាលាក្តីខ្មែរក្រហម សរុបចំនួនជាង ៨២ លានដុល្លារសហរដ្ឋអាមេរិក ស្មើប្រមាណ ៣៦ ភាគរយនៃជំនួយថវិកាសរុប ដែលប្រទេសម្ចាស់ជំនួយផ្តល់ដល់ អ.វ.ត.ក។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាលនៃអ.វ.ត.ក បានមានប្រសាសន៍ថា៖ “ក្នុងនាមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះរដ្ឋាភិបាលជប៉ុនសម្រាប់ការបន្តគាំទ្រតុលាការនេះ”។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក **ឡាស អលសិន**
មន្ត្រីទំនាក់ទំនងច្បាប់
ទូរស័ព្ទដៃ: +៨៥៥(០)១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥(០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិច: olsenl@un.org

លោក **នេត្រ ភក្ត្រា**
មន្ត្រីអ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥(០)១២ ៤៨៨ ១៥៦
ទូរស័ព្ទ: +៨៥៥(០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិច: neth.pheaktra@eccc.gov.kh